# តំបន់កណ្តាលនៃជួរភ្នំក្រវាញ A1 & A2



| | | |
|---|---|---|
| **ខេត្ត** | : | ពោធិសាត់ កំពង់ស្ពឺ និង កោះកុង |
| **ស្រុក** | : | ក្រវាញ ឱរ៉ាល់ វាលវែង និង ថ្មបាំង |
| **ផ្ទៃដី ( ហិកតា)** | : | ៣៨៥.៣៦២ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៣៥០ ដល់ ១.៥៣៩ |
| **កូអរដោនេចំណុចកណ្តាល** | : | ១១°៥៣' ជ ១០៣° ៣២' ក |

**ការពិពណ៌នាទីកន្លែង**

តំបន់ IBA នេះ ស្ថិតនៅក្នុងតំបន់ជួរភ្នំក្រវាញរវាងតំបន់ IBA ភ្នំសំកុះ (KH012) និង ភ្នំឱរ៉ាល់ (KH014) ។ តំបន់នេះរួមមានតំបន់ព្រៃស្រោង និង ព្រៃរបោះនៃជួរភ្នំក្រវាញ ដែលមានរយៈកំពស់លើសពី៤០០ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ ដែលគេគិតថា ជារយៈកំពស់មួយទាបជាងរយៈកំពស់របស់តំបន់ក្រួចសំពៅរស់នៅ ។ តាមលក្ខណៈសណ្ឋានដី តំបន់នេះសម្បូរទៅដោយភ្នំ ដែលមានកំពូលទាបជាងតំបន់ IBA ផ្សេងៗដែលស្ថិតនៅក្បែរៗ ។ រុក្ខជាតិក្នុងតំបន់នេះគ្របដណ្តប់ដោយព្រៃស្រោងតំបន់ទំនាប ជាមួយនឹងព្រៃស្រោងតំបន់ភ្នំដែលមានរយៈកំពស់លើសពី១.០០០ម៉ែត្រ ។ តំបន់ IBA នេះបានទ្រទ្រង់ប្រភេទក្រួចសំពៅដែលជាប្រភេទមួយក្នុងចំណោមពីរប្រភេទមានដែនកំណត់នៅតាមជួរភ្នំប្រទេសកម្ពុជា និង ប្រទេសថៃប៉ុណ្ណោះ ។ លើសពីនេះទៀត វិសាលភាពយ៉ាងធំនៃតំបន់ព្រៃស្រោងព្រហ្មចារីនៅក្នុងតំបន់ IBA នេះ ធ្វើឱ្យវាមានសារៈសំខាន់សម្រាប់ការអភិរក្សនៃប្រភេទកេងកងធំ ។ យោងតាមកំណត់ត្រាជាប្រវត្តិសាស្ត្រទាំងប្រភេទទាព្រៃស្លាបស និង ត្រយ៉ងចំកំកសត្រូវបានគេកត់ត្រានៅតាមបណ្តោយទន្លេក្នុងតំបន់ IBA នេះនៅក្នុងឆ្នាំ ១៩៩៤ ប៉ុន្តែស្ថានភាពបច្ចុប្បន្នមិនបានដឹងនៅឡើយ ។ តំបន់នេះភាគច្រើនគឺស្ថិតនៅក្នុងតំបន់ព្រៃអភិរក្សជួរភ្នំក្រវាញ ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 |
| ក្រួចសំពៅ | Chestnut-headed Partridge | *Arborophila cambodiana* | A1 |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ្ជីប្រផេះ ស្វាត្រោស ស្វាក្តាម ស្វាអង្កត់ និង ទោចម្កុដ ។

**ដំរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

ដំរី ខ្ទីង និង កែះ ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

ក្រពើទន្លេ (ក្រពើត្រី) អណ្តើកគីកកាល់បន្ទាមួយ និង កន្ធាយអាស៊ី ។

## ការគំរាមកំហែងលើជីវៈចំរុះ

ការស្ថាបនាផ្លូវថ្មីៗ និង ផ្លូវក្នុងតំបន់ព្រៃសម្បទានគឺធ្វើឱ្យមានលក្ខណៈងាយស្រួលក្នុងការចេញ ចូលទៅកាន់តំបន់នោះសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន ជាពិសេសមកកាន់តំបន់ទំនាប ដែលនាំឱ្យមានការប្រែក្លាយតំបន់ដីព្រៃឈើទៅជាតំបន់កសិកម្ម ។ ការប្រមាញ់កើតមានច្រើនក្នុងតំបន់នេះដោយសារមានផ្លូវថ្មីៗគឺជាបញ្ហាមួយផងដែរចំពោះសត្វព្រៃគ្រប់ប្រភេទដែលផលប្រមាញ់ភាគច្រើនត្រូវបានប្រើប្រាស់នៅក្នុងភូមិ ។ ដោយឡែកការប្រមាញ់សម្រាប់ធ្វើពាណិជ្ជកម្ម ពិសេសសម្រាប់នាំចេញទៅប្រទេសថៃមានការកើនឡើងព្រមទាំងការរុករកប្រភេទខ្លឹមច័ន្ទ (*Aquilaria* species) ។

## អនុសាសន៍

ការអនុវត្តន៍ច្បាប់លើការបង្ក្រាបការបរបាញ់ និង ការធ្វើពាណិជ្ជកម្មសត្វព្រៃ ព្រមទាំងសកម្មភាពកាប់បំផ្លាញព្រៃឈើគួរតែត្រូវបានពង្រឹងនៅក្នុងតំបន់ជួរភ្នំក្រវាញទាំងមូល ។

ការអភិវឌ្ឍន៍ណាមួយនៅក្នុងតំបន់ដោយគ្មានការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវតែហាមឃាត់ ឬ បញ្ឈប់តែម្តង ។ ការទន្រ្ទានយកដី និង ការរានដីព្រៃឈើសម្រាប់ជាគោលបំណងកសិកម្មមិនគួរអនុញ្ញាតឡើយ ។

## ឯកសារយោង


Eames, J. C. and Steinheimer, F. (2000) Birds. In J. C. Daltry and Momberg, F. eds. *Cardamom mountains biodiversity survey 2000*. Hanoi and Phnom Penh: Fauna & Flora International and the Wildlife Protection Office.

Engelbach, P. (1952) Notes de voyage dans les Monts des Cardamomes (Cambodge). *L'Oiseau et la Revue Francai se d'Ornithologie.* 22: 283-302.

Swan, S. R. and Long, B. (2002) Birds. In J. C. Daltry ed. *Social and ecological surveys of Phnom Aural Wildlife Sanctuary, Cardamom mountains, Cambodia*. Phnom Penh: Fauna & Flora International Cambodia Program me.